# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ ធម៌៤បទជាពុទ្ធភាសិតដែលនាំឲ្យឈ្នះ

www.hoksavann,com

ថ្ងៃទី១៨ វិច្ឆិកា ២០១០



ធម៌៤បទជាពុទ្ធភាសិតដែលនាំឲ្យឈ្នះ គឺធម្មទានរមែងឈ្នះនូវទានទាំងពួង រសនៃព្រះធម៌រមែងឈ្នះនូវរសទាំងពួង សេចក្តីត្រេកអរក្នុងធម៌រមែងឈ្នះនូវសេចក្តីត្រេកអរទាំងពួង ការអស់ទៅនៃតណ្ហារមែងឈ្នះនូវសេចក្តីទុក្ខទាំងពួងនេះ ចេញមកពីបាលីថា សព្វទានំ ធម្មទានំ ជិនាតិ សព្វរសំ ធម្មរសោ ជិនាតិ សព្វរតឹ្ត ធម្មរតិ ជិនាតិ តណ្ហក្ខយោ សព្វទុក្ខំ ជិនាតិ ។

ពាក្យថា ធម្មទានរមែងឈ្នះនូវទានទាំងពួង មានសេចក្តីថា ទានប្រែថាការមានពីរយ៉ាងគឺ អាមិសទាន ការឲ្យវត្ថុផ្សេងៗជាទាន និងធម្មទានប្រែថាការឲ្យទានធម៌ គឺការប្រាប់ពន្យល់បាបបុណ្យគុណទោសល្អអាក្រក់, ការប្រាប់មធ្យោបាយផ្សេងៗ ដែលនាំទៅរកសេចក្តីសុខចំរើន តាមមាគ៌ាព្រះពុទ្ធសាសនា ។ ទានទាំងពីរនេះ ធម្មទានរមែងឈ្នះអាមិសទាន ព្រោះថាអាមិសទានដែលលះវត្ថុផ្សេងៗធ្វើជាទានឲ្យបានត្រឹមត្រូវ មកពីបានស្តាប់ពាក្យប្រៀនប្រដៅរបស់អ្នកសប្បុរសទាំងឡាយមានព្រះពុទ្ធជាដើម គឺធម្មទាននេះឯង ។ ឧទាហរណ៍ ការឲ្យផ្លែស្វាយមួយទទួលទានតែម្តងក៏អស់ទៅ ប៉ុន្តែបើគេឲ្យប្រាប់យកទៅដាំ ហើយប្រាប់មធ្យោបាយដាំ លុះស្វាយនោះដុះជាដើម បែកជាមែក មានផ្កាផ្លែ គេនឹងបេះបានរាល់ឆ្នាំ នេះដោយសារការប្រាប់វិធីដាំ ដែលហៅថាធម្មទាននេះឯង ។

ពាក្យថា រសនៃព្រះធម៌រមែងឈ្នះរសទាំងពួង មានសេចក្តីថា រសទាំងឡាយដូចជារសក្នុងកាមគុណ៥ មានការសប្បាយរីករាយតែមួយខណៈមួយពេល ដោយការប៉ះអារម្មណ៍ក៏បាត់ទៅវិញ ។ ការឮសម្លេង បើសម្លេងនោះជាទីគាប់ចិត្ត ក៏បានរីករាយតែមួយរយៈពេលខ្លីក៏បាត់ទៅវិញ ។ ការធុំក្លិនក្រអូប ធ្វើឲ្យចិត្តរីករាយបានតែមួយភ្លែតក៏បាត់ទៅវិញ ។ អណ្តាតបានប៉ះរសជាតិអាហារឆ្ងាញ់ ពិសារបានតែមួយរយៈពេល លុះលេបផុតពីបំពង់កទៅ ការឆ្ងាញ់ពិសារនោះក៏បាត់ទៅ ។ កាយប៉ះផោដ្ឋព្វៈគឺប៉ះរបស់ល្អប្រណីតធ្វើឲ្យកាយសុខស្រួលបានតែមួយពេលក៏បាត់ទៅវិញ ។ ចិត្តនឹកគិតអារម្មណ៍ជាទីគាប់ចិត្តបានរីករាយចិត្តតែមួយខណៈក៏បាត់ទៅវិញ ។ រសជាតិនៃសេចក្តីសុខនេះ លោកហៅថាកាមសុខ ឬអាមិសសុខ គឺសុខដោយការប៉ះអារម្មណ៍ ។ ឯរសរបស់ព្រះធម៌ គឺសីលសមាធិបញ្ញា បើបុគ្គលណាបានប្រតិបត្តិតាមនឹងរួចចាកទុក្ខ គឺវិមុត្តិរស ឬនិព្វានរសចេញផុតពីការកើតចាស់ឈឺស្លាប់ ។

ពាក្យថា សេចក្តីត្រេកអរក្នុងធម៌ រមែងឈ្នះនូវសេចក្តីត្រេកអរទាំងពួង មានសេចក្តីថា ការត្រេកអរក្នុងធម៌ រីករាយក្នុងធម៌ ស្រឡាញ់ធម៌ ហើយធ្វើតាមធម៌ គឺប្រតិបត្តិតាមមគ្គប្រកបដោយអង្គ៨ បើរួមឲ្យខ្លីបានដល់សីលសមាធិបញ្ញា ដែលព្រះពុទ្ធបានរកឃើញ ជាផ្លូវនៃសេចក្តីបរិសុទ្ធ ជាផ្លូវនៃការចេញចាកទុក្ខ បានដល់ព្រះនិព្វាន ឆ្លងផុតពីភពបី ដែលជាភពស្ថិតនៅក្រោមអនិច្ចំ ទុក្ខំ អនត្តា ។ ដូច្នេះសេចក្តីត្រេកអរក្នុងធម៌ ហើយប្រតិបត្តិតាមនឹងបានចាកទុក្ខ ឯសេចក្តីត្រេកអរផ្សេងពីព្រះធម៌ ដូចជាត្រេកអរក្នុងកាមគុណ៥មានរូបជាដើម ពុំអាចធ្វើទុក្ខឲ្យអស់ទៅបានឡើយ ។

ពាក្យថា ការអស់ទៅនៃតណ្ហា រមែងឈ្នះនូវសេចក្តីទុក្ខទាំងពួង មានសេចក្តីថា សេចក្តីទុក្ខកើតមានព្រោះមានហេតុនាំឲ្យមានទុក្ខ ។ ក្នុងអរិយសច្ច៤ ប្រែថា ការពិត៤យ៉ាង ទីមួយគឺសេចក្តីទុក្ខ បានដល់ការកើតឡើងនៃខន្ធ៥ មានរូបខន្ធជាដើម ត្រូវកំណត់ដឹង ។ ទីពីរហេតុដែលនាំឲ្យកើតទុក្ខ បានដល់តណ្ហាត្រូវលះបង់ ។ ទីបីនិរោធសច្ច បានដល់ព្រះនិព្វាន ត្រូវធ្វើឲ្យជាក់ច្បាស់ ។ ទីបួនមគ្គសច្ច បានដល់មគ្គប្រកបដោយអង្គ៨ ត្រូវចំរើនឲ្យកើតឡើង ។ ដូច្នេះពុទ្ធភាសិតថាការអស់ទៅនៃតណ្ហារមែងឈ្នះនូវសេចក្តីទុក្ខទាំងពួង គឺប្រតិបត្តិតាមមគ្គ៨ទើបអស់ទៅនៃតណ្ហា ទើបធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានជាការរំលត់ទុក្ខ គឺរំលត់នូវខន្ធ៥ កុំឲ្យកើតមានតទៅទៀត ព្រោះការកើតឡើងនៃខន្ធ៥នេះហើយ ដែលនាំឲ្យកើតចាស់ឈឺស្លាប់ក្នុងសង្សារវដ្តរកទីបំផុតគ្មាន បើគេពុំឃើញអរិយសច្ច៤នេះទេ ។៚

✪ ✪

✪

ប្រ

☆ ☆

☆